ក្រសួងបរិស្ថាន

# ភ្នំគូលែន

## រាជធានីពិសិដ្ឋនៃចក្រភពខ្មែរ

LL
338
SEN

២០០៥

www.elibraryofcambodia.org

Dau
DoB
L 338
SEN

ក្រោមការដឹកនាំរបស់

ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ឯកឧត្តម **ចាយ សាមិត្ត** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា

ទទួលបន្ទុកជាអគ្គនាយករដ្ឋបាល ការពារ និង អភិរក្សធម្មជាតិ

ព្រះរាជាណាចក្រកម្ពុជា
18311/15
4/5
បណ្ណាល័យជាតិ
National Library of Cambodia
00051333452
www.elibraryofcambodia.org

ស្រាវជ្រាវនិងចងក្រង ៖ លោក សេង សោត

ពិនិត្យអក្ខរាវិរុទ្ធ ៖ លោកស្រី កែម សុនីន, កញ្ញា សយ សោភ័ណ និង កញ្ញា កែវ នាទី

រចនាទំព័រ ៖ លោក លឹម វណ្ណចន្ទ និង លោក សាខឿន សក្កា

រក្សាសិទ្ធិដោយ ក្រសួងបរិស្ថាន

ខែមីនា ឆ្នាំ២០១៥

www.elibraryofcambodia.org

# មាតិកា


១-សេចក្តីផ្តើម ....................................... ១

២-ធនធានធម្មជាតិ ....................................... ២

៣-មត៌កវប្បធម៌ ....................................... ៤

៣-១-ប្រាសាទបុរាណ ....................................... ៦

៣-២-តើង ....................................... ៩

៣-៣-ចម្លាក់បាតស្ទឹង ....................................... ១១

៣-៤-ចម្លាក់ព្រះពុទ្ធរូប ....................................... ១២

៣-៥-ទំនប់បុរាណ ....................................... ១៤

៣-៦-ឡបុរាណ ....................................... ១៥

៣-៧-ជណ្តើរបុរាណ ....................................... ១៧

៣-៨-ស្រះដំរី ....................................... ១៨

៣-៩-ការដ្ឋានយកថ្មបុរាណ ....................................... ១៩

៤-សហគមន៍មូលដ្ឋាន ....................................... ២០

៥-ទិសដៅអភិរក្ស និងអភិវឌ្ឍន៍ ....................................... ២១

៦-សេចក្តីសន្និដ្ឋាន ....................................... ២១

បញ្ជីប្រាសាទ ....................................... ២៣

បញ្ជីតើង ....................................... ២៦


www.elibraryofcambodia.org

# ១-សេចក្តីផ្តើម

ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម "ភ្នំគូលែន" ត្រូវបានបង្កើតឡើង និងកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដោយមានផ្ទៃដីសរុបចំនួន៣៧៥០០ហិកតា ដែលមានវិសាលភាពគ្របដណ្តប់លើភ្នំចំនួនបីគឺ ភ្នំហប់ ភ្នំគូលែន និងភ្នំក្បាលស្ពាន។ ភ្នំនីមួយៗមិនត្រឹមតែមានតួនាទីសំខាន់ក្នុងការជួយរក្សាលំនឹងបរិស្ថាននៅតំបន់អង្គរ តាមរយៈប្រភពធនធានធម្មជាតិដ៏សម្បូរបែប មានព្រៃឈើ ប្រភពទឹក និងជីវចម្រុះប៉ុណ្ណោះទេ ប៉ុន្តែវាមានអត្ថន័យជ្រៅជ្រះ និងមានតម្លៃជាប្រវត្តិសាស្ត្រសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដោយសារសំណង់ប្រវត្តិសាស្ត្រ និងស្ថានីយ៍បុរាណជាច្រើនកន្លែងត្រូវបានរកឃើញនៅទីនោះ។ កន្លងមកភ្នំគូលែនធ្លាប់ទទួលបានងារជា "ឧទ្យានជាតិ" តាមរយៈព្រះរាជក្រឹត្យកាលពីឆ្នាំ១៩៦៩ ហើយបានក្លាយជាឧទ្យានជាតិទី២ បន្ទាប់ពីអង្គរដែលជាឧទ្យានជាតិទី១ ត្រូវបានការពារ និងកំណត់ដោយព្រះរាជក្រឹត្យ កាលពីឆ្នាំ១៩២៥។

ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម"ភ្នំគូលែន" មានទីតាំងស្ថិតនៅក្នុងស្រុកចំនួនបី ៖ ស្រុកស្វាយលើ (ប៉ែកខាងកើត និងខាងជើង) ស្រុកបន្ទាយស្រី (ប៉ែកខាងត្បូង) និងស្រុកវ៉ារិន (ប៉ែកខាងលិច) ហើយក៏ គ្របដណ្តប់លើឃុំចំនួនពីរគឺ ឃុំខ្នងភ្នំនៃស្រុកស្វាយលើ និងឃុំឃុនរៀមនៃស្រុកបន្ទាយស្រី។ ម្យ៉ាងទៀត ឧទ្យានជាតិនេះព័ទ្ធជុំវិញដោយឃុំចំនួនបួនគឺ ឃុំបេងមាលា ឃុំកន្ទួត និងឃុំតាសោមនៃស្រុកស្វាយលើ និងឃុំត្បែងនៃស្រុកបន្ទាយស្រី។



**ស្ថានភាពដីភ្នំគូលែន និងតំបន់អង្គរ**

ភ្នំគូលែននិយាយដោយឡែកជាភ្នំមួយមានទំហំធំជាងគេក្នុងចំណោមភ្នំតូចៗ ដូចបានបញ្ជាក់ជូនខាងលើ ដែលមាន

www.elibraryofcambodia.org

ទីតាំងស្ថិតនៅចំទិសឦសាន និងមានចំងាយប្រមាណ៤០គីឡូម៉ែត្រពីទីរួមខេត្តសៀមរាប។ ធម្មជាតិវិទូបារាំងឈ្មោះ ហង់រី មូហូត (H. Mouhot) ដែលបានទៅដល់ភ្នំគូលែនកាលពីពាក់កណ្តាលសតវត្សទី១៩ បានចាត់ទុកភ្នំនេះថាជា "ខ្ពង់រាប" ដោយសារខ្នងភ្នំមានសណ្ឋានជាវាលទំនាប ដែលមានវិសាលភាពធំល្វឹងល្វើយលាតសន្ធឹងតាមបណ្តោយជួរភ្នំ និងគ្របដណ្តប់ទៅដោយព្រៃក្រាស់ ហើយមានកំពស់ប្រែប្រួលពី៣០០ម៉ែត្រទៅ៤០០ម៉ែត្រ និងមានបណ្តោយប្រវែង៣៨គីឡូម៉ែត្រ។

ភ្នំគូលែនជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់មួយដែលបានបន្សល់ទុកនូវប្រាសាទបុរាណ និងស្ថានីយ៍បុរាណច្រើនកន្លែង រួមទាំងមានសហគមន៍មនុស្សផងដែរ។ ម្យ៉ាងទៀតភ្នំនេះបានក្លាយជាប្រធានបទដ៏សំខាន់ សម្រាប់អ្នកសិក្សាស្រាវជ្រាវទាំងឡាយ ចាប់តាំងពីចុងសតវត្សទី១៩ រហូតមកដល់បច្ចុប្បន្ន ក្នុងនោះយើងឃើញមានការសិក្សាស្រាវជ្រាវ និងវិភាគទៅលើសំណង់បុរាណ វត្ថុសិល្បៈ សិលាចារឹក ព្រៃឈើ និងប្រព័ន្ធផ្លូវទឹកធម្មជាតិនានា។

## ២-ធនធានធម្មជាតិ

ភ្នំគូលែនគ្របដណ្តប់ដោយព្រៃស្រោង ដែលជាប្រភពធនធានដ៏សំខាន់មួយក្នុងការទាក់ទាញទឹកភ្លៀង។ អ្នកស្រាវជ្រាវបារាំងមួយរូបឈ្មោះ ហ្សង់ ប៊ូលបេ (J. Boulbet) ដែលបានសិក្សាអំពីភូមិសាស្ត្រតំបន់ភ្នំគូលែនកាលពីពាក់កណ្តាលសតវត្សទី២០បានបញ្ជាក់ថា ភ្លៀងចាប់ផ្តើមធ្លាក់នៅតំបន់ភ្នំគូលែនមុនតំបន់វាលទំនាបនៃខេត្តសៀមរាប ដោយចាប់ផ្តើមនៅរវាងខែមីនា ឬមេសា។ ការសិក្សាខាងលើនេះបានបញ្ជាក់ឲ្យដឹងថាតំបន់ភ្នំគូលែនទទួលទឹកភ្លៀងច្រើនក្នុងមួយឆ្នាំៗ។ ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំនៅតំបន់ភ្នំគូលែនមានចំនួន២០០០មីលីម៉ែត្រ។ ហេតុនេះភ្នំគូលែនជាប្រភពទឹកធម្មជាតិដ៏សំខាន់សម្រាប់ចិញ្ចឹមតំបន់វាលទំនាបខាងក្រោម។

តាមការសិក្សារបស់លោក វ៉ាន់ លីអែរ (Van Liere) កាលពីឆ្នាំ២០១២កន្លងទៅ តំបន់ភាគខាងត្បូងនៃខ្នងភ្នំគូលែនមានសណ្ឋានជារាងបាតខ្ទះប្រៀបដូចជាអាងស្តុកទឹកធំមួយដែលបើកចំហមកទិសពាយព្យ។ ទឹកភ្លៀងត្រូវបានស្ថិតនៅមួយរយៈក្នុងអាងស្តុកទឹកធម្មជាតិនោះដែលអ្នកស្រុកហៅថា "អន្លង់" ។


www.elibraryofcambodia.org

បន្ទាប់មកក៏ហូរចុះមកក្រោមតាមប្រព័ន្ធផ្លូវទឹកធម្មជាតិតូចៗជាច្រើន នៅលើខ្នងភ្នំ ដែលប្រមូលផ្តុំទឹកទៅចាក់បំពេញឲ្យបណ្តាញផ្លូវទឹកធំៗខាងក្រោមមុននឹងហូរចាក់ទៅបឹងទន្លេសាប។ ម៉្យាងទៀតទឹកដែលហូរធ្លាក់ពីប្រព័ន្ធផ្លូវទឹកខាងលើនោះ បានប្រមូលផ្តុំបង្កើតជាតំបន់ទឹកធ្លាក់ដ៏សែនមនោរម្យមួយ ដែលទាក់ទាញបាននូវភ្ញៀវទេសចរជាតិ និងអន្តរជាតិ។



**ទឹកជ្រោះភ្នំគូលែន**

ប្រព័ន្ធផ្លូវទឹកធម្មជាតិដែលមានប្រភពពីភ្នំគូលែនបាននាំទឹកហូរធ្លាក់ចុះស្របទៅតាមសណ្ឋានដីដែលមានលក្ខណៈជម្រាលដោយខ្ពស់ពីទិសឦសាននិងធ្លាក់ចុះទាបទៅទិសនិរតី រហូតដល់បឹងទន្លេសាប ក្នុងនោះមានស្ទឹងសៀមរាប ស្ទឹងពួក និងស្ទឹងរលួស។ ចំណែកនៅតំបន់ប៉ែកខាងក្រោមនៃតំបន់ភ្នំគូលែនគឺជាវាលទំនាបលាតសន្ធឹងល្វឹងល្វើយដែលអំណោយផលដល់ការធ្វើកសិកម្មនិងតាំងទីលំនៅ។ ចាប់តាំងពីសម័យបុរាណតរៀងមក ប្រជារាស្ត្រខ្មែរបានមកតាំងទីលំនៅយ៉ាងច្រើនកុះករនៅតាមតំបន់វាលទំនាបជិតបឹងទន្លេសាប ដោយការពឹងផ្អែកលើប្រព័ន្ធផ្លូវទឹកទាំងឡាយខាងលើដែលមានប្រភពពីភ្នំគូលែន។

ម៉្យាងទៀតប្រព័ន្ធផ្លូវទឹកធម្មជាតិទាំងនោះបានផ្តល់សារប្រយោជន៍ដល់ការធ្វើទំនាក់ទំនងពីកន្លែងមួយទៅកន្លែងមួយ ក្នុងនោះស្ទឹងសៀមរាបមានតួនាទីសំខាន់សម្រាប់ជាផ្លូវគមនាគមន៍ដែលសម្រួលដល់ការដឹកជញ្ជូនទំនិញ និងការធ្វើទំនាក់ទំនងទាំងក្នុងស្រុក និងក្រៅស្រុកទៀតផង។ ឯកសារជាច្រើនបានបង្ហាញអំពីការដឹកជញ្ជូនភោគផល និងសម្ភារៈផ្សេងៗ ពីតំបន់នានាមករាជធានីអង្គរ និងការធ្វើទំនាក់ទំនងតាមផ្លូវទឹកជាមួយពិភពខាងក្រៅ។

www.elibraryofcambodia.org



ផ្លូវទឹកនៅភូមិអន្លង់ធំ

បច្ចុប្បន្នស្ទឹងសៀមរាប ស្ទឹងរលួស និងស្ទឹងពួក ថ្វីត្បិតតែមានទំហំតូចប៉ុន្តែវាជាប្រព័ន្ធផ្លូវទឹកដ៏សំខាន់មួយក្នុងការធានាផ្គត់ផ្គង់ទឹកដល់ជីវិតសត្វ រុក្ខជាតិ និងមនុស្សព្រមទាំងកំពុងជួយថែរក្សាប្រាសាទបុរាណនានាក្នុងតំបន់អង្គរទៀតផង។ ហេតុនេះតំបន់ភ្នំគូលែនគឺជា "ប្រភពទឹក" ដ៏ចំបង និងចាំបាច់បំផុតក្នុងការជួយថែរក្សាជីវចម្រុះឲ្យបានគង់វង្ស ធ្វើឲ្យមានលំនឹងធម្មជាតិ និងផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅតំបន់អង្គរ។

ក្រៅពីប្រភពទឹក ភ្នំគូលែនជាតំបន់ថ្មភក់ដ៏ធំមួយ។ ក្នុងនោះ លោក ហង់រី មូហូត ដែលបានសិក្សាអំពីភូមិសាស្ត្រនៃតំបន់ភ្នំគូលែន បានបញ្ជាក់ឲ្យដឹងថា "តំបន់ភ្នំគូលែនសម្បូរទៅដោយថ្មភក់..."។ ថ្មភក់ភ្នំគូលែនមានតួនាទីសំខាន់ក្នុងប្រវត្តិសាស្ត្រជាពិសេសនៅសម័យអង្គរចាប់ពីសតវត្សទី៩ ដោយសារសំណង់ប្រាសាទបុរាណជាច្រើននៅរាជធានីអង្គរបានប្រើប្រាស់ថ្មភក់ ដែលយកចេញពីតំបន់ភ្នំគូលែន មានដូចជាការដ្ឋានអូរថ្មដាប់ ដែលជាការដ្ឋានយកថ្មធំជាងគេនៅតំបន់ភ្នំគូលែន មានទីតាំងស្ថិតនៅឃុំបេងមាលា ក្នុងស្រុកស្វាយលើ។

## ៣-មត៌កវប្បធម៌

ដូចបានបញ្ជាក់ជូនខាងលើ អ្នកសិក្សាស្រាវជ្រាវបារាំងឈ្មោះ ហង់រី មូហូត (H. Mouhot) ជាមនុស្សដំបូងដែលបានទៅដល់ និងកត់ត្រាព័ត៌មានគ្រួសៗអំពីតំបន់ភ្នំគូលែន។ តាមរយៈព័ត៌មានតិចតួចរបស់លោក អ្នកសិក្សាស្រាវជ្រាវជាបន្តបន្ទាប់បានចាប់អារម្មណ៍និងធ្វើការស្រាវជ្រាវនៅតំបន់ភ្នំគូលែន។

រហូតមកដល់ឆ្នាំ១៩២៧ លោក ហង់រី ប៉ាម៉ង់ត្យេ (H. Parmantier) បានធ្វើការកត់ត្រា និងសិក្សាប្រាសាទមួយ



www.elibraryofcambodia.org

ចំនួននៅលើភ្នំគូលែន មានដូចជាប្រាសាទដំរីក្រាប ប្រាសាទអូរផ្អុង ប្រាសាទអ្នកតា និងប្រាសាទក្រហម ជាដើម។ ចាប់ពីពេលនេះមក អ្នកស្រាវជ្រាវបារាំងបានបង្កើនការស្វែងយល់អំពី ប្រវត្តិសាស្ត្រខ្មែរ ដោយបានសិក្សាលម្អិតទៅលើសំណង់ស្ថាបត្យកម្មបុរាណនានា សិលាចារឹក និងរូបបដិមាជាដើម។

ជាងដប់ឆ្នាំក្រោយមកទៀត រមណីយដ្ឋានភ្នំគូលែនត្រូវបានសិក្សាយ៉ាងហ្មត់ចត់ ពីសំណាក់អ្នកស្រាវជ្រាវបារាំង។ លោក ហ្វីលីព ស្ទែន (Ph. Stern) ជាអភិរក្សករនៅសារមន្ទីរហ្គីម៉េ នៃទីក្រុងប៉ារីស បានលើកយក "បញ្ហាភ្នំគូលែន" មកសិក្សាលំអិត ដោយមានការធ្វើកំណាយស្រាវជ្រាវច្បាស់លាស់។ ការធ្វើកំណាយតាមបែបបុរាណវិទ្យា ដើម្បីសិក្សាស្រាវជ្រាវនោះបានចាប់ផ្តើមឡើង នៅអំឡុងខែមេសា ក្នុងឆ្នាំ១៩៣៦ និងបានជួលកម្មករខ្មែរបួនប្រាំនាក់ចូលរួមសម្រាប់បេសកកម្មនេះ។ ជាលទ្ធផលប្រាសាទបុរាណថ្មីចំនួន១៧ត្រូវបានរកឃើញ រួមទាំងវត្ថុបុរាណ និងស្ថានីយ៍បុរាណជាច្រើនកន្លែងទៀតនៅលើផ្ទៃដីទំហំ៥ គីឡូម៉ែត្រការ៉េ។ តាមរយៈការស្រាវជ្រាវនេះគេមានភាពជាក់លាក់ក្នុងការចាត់បញ្ចូលសំណង់ ប្រាសាទបុរាណ រូបចម្លាក់ រួមទាំងស្ថានីយ៍បុរាណនៅលើភ្នំគូលែន ឲ្យស្ថិតនៅក្នុងសម័យកាលនៃព្រះបាទជ័យវរ្ម័នទី២ នាដើមសតវត្សទី៩ ដោយដាក់ឈ្មោះថា "រចនាបទគូលែន"។

ទោះជាយ៉ាងណាក៏ការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យា នៅលើភ្នំគូលែនមិនទាន់ត្រូវបានបញ្ចប់នៅឡើយទេ។ រហូតមកដល់ដើមសតវត្សទី២១នេះ ស្លាកស្នាម និងទីតាំងបុរាណមួយចំនួនទៀតត្រូវបានរកឃើញ។ ប៉ុន្តែប្រាសាទបុរាណដែលត្រូវបានរកឃើញនាសម័យកាលក្រោយមកនោះជាទូទៅពុំបានបន្សល់ទុកនូវរូបភាពសំណង់គួរឲ្យកត់សំគាល់នោះទេ គឺនៅសល់តែគ្រឿងលំអរស្ថាបត្យកម្ម មានដូចជា ផ្តែរទ្វារ សុំទ្វារ សសរពេជ្រ ឥដ្ឋ ថ្មបាយក្រៀម ឬជើងទម្ររូបចម្លាក់តែប៉ុណ្ណោះ។ ម៉្យាងទៀតទីតាំងប្រាសាទបុរាណទាំងនោះពុំទាន់មានឈ្មោះច្បាស់លាស់នៅឡើយ។ រហូតមកដល់ពេលនេះចំនួន៤៨កន្លែង។

ក្រៅពីសំណង់ប្រាសាទ តំបន់ភ្នំគូលែនបានលាក់ទុកនូវស្ថានីយ៍បុរាណល្អៗជាច្រើនកន្លែងទៀត មានដូចជាពើង (ផ្ទាំងចម្លាក់ជារូបផ្សេងៗនៅលើជញ្ជាំងថ្មភ្នំ) ជាច្រើនកន្លែងទៀត ជាពិសេស ផ្ទាំងចម្លាក់រូបបដិមា រួមទាំងចម្លាក់លឹង្គព្រះសិវៈជាច្រើនដែលត្រូវបានឆ្លាក់នៅលើផ្ទាំងសិលាក្រាលពាសបាតអូរ និងមានទឹកហូរឆ្លងកាត់។ ចម្លាក់របៀបនេះបង្ហាញពីលក្ខណៈពិសេសគ្មានពីរ នៅព្រះរាជាណាចក្រកម្ពុជា ដែលដូនតាខ្មែរ

www.elibraryofcambodia.org



ប្រាសាទអូរផ្អុង

បានបង្កើតឡើងដើម្បីបំរើឲ្យជំនឿសាសនា ហើយជាវិធីដើម្បីកែប្រែស្ទឹងសៀមរាប ទាំងមូលឲ្យក្លាយទៅជាទន្លេគង្គា ដែលមានទឹកបរិសុទ្ធ។ ទីតាំងនៃចម្លាក់លឹង្គដ៏ច្រើនស្ថិតនៅបាតនៃប្រភពទឹកទាំងនោះមានឈ្មោះថា "លឹង្គមួយពាន់"។

## ៣-១-ប្រាសាទបុរាណ

តាមរយៈការស្រាវជ្រាវ និងរុករកនៅលើភ្នំគូលែនចាប់តាំងពីចុងសតវត្សទី១៩មក ប្រាសាទបុរាណជាច្រើនត្រូវបានកត់ត្រា និងចុះក្នុងបញ្ជីសារពើភណ្ឌប្រាសាទបុរាណ។ ប្រាសាទបុរាណទាំងនោះភាគច្រើនត្រូវបានកសាងឡើងក្នុងរាជព្រះបាទជ័យវរ្ម័នទី២ នាដើមសតវត្សទី៩។ ពិនិត្យជារួមប្រាសាទបុរាណដែលត្រូវបានរកឃើញរហូតមកដល់សព្វថ្ងៃនេះ ភាគច្រើនត្រូវបានកសាងឡើងអំពីឥដ្ឋជាប្រភេទសំណង់ទោលដែលមានតួប៉មតែមួយនៅលើខឿនអំពីថ្មបាយក្រៀម និងមានកំពែងអំពីឥដ្ឋ(ប្រាសាទអូរផ្អុង ប្រាសាទអ្នកតា ប្រាសាទខ្ទឹងស្លាប់ជាដើម) និងប្រាសាទមួយចំនួនទៀតជាប្រភេទសំណង់ ដែលមានតួប៉មច្រើនស្ថិតនៅជាជួរ ហើយព័ទ្ធជុំវិញដោយកំពែងអំពីថ្មបាយក្រៀម (ប្រាសាទដំរីក្រាប និងប្រាសាទប្រាំ)។ ចំណែកប្រាសាទក្រោលរមាស ជា


www.elibraryofcambodia.org

ប្រភេទសំណង់អំពីថ្មបាយក្រៀម ទាំងតួប៉ម ថែវ និងកំពែងព័ទ្ធជុំវិញ លើកលែងគ្រឿងលំអស្ថាបត្យកម្ម ដែលរចនានៅលើថ្មភក់។ ប្រាសាទនេះត្រូវបានកសាងឡើងក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ នាសតវត្សទី១៣។

នៅអំឡុងដើមសតវត្សទី២០ប្រាសាទមួយចំនួនត្រូវបានរកឃើញនៅលើភ្នំគូលែនមានដូចជា ប្រាសាទដំរីក្រាប ប្រាសាទអូរផ្អុង ប្រាសាទអ្នកតា ប្រាសាទក្រហមជាដើម។ លុះមកដល់ឆ្នាំ១៩៣៦ ប្រាសាទបុរាណមួយចំនួនទៀតត្រូវបានរកឃើញមានដូចជាប្រាសាទបួសនាគ ប្រាសាទរោងចិន ប្រាសាទរូបអារក្ស ប្រាសាទខ្លាឃ្មុំជាដើម។ តាមរយៈសំណង់ស្ថាបត្យកម្មបុរាណទាំងនោះ អ្នកសិក្សាស្រាវជ្រាវបារាំងឈ្មោះ ហ្វីលីព ស្ទែន ( Ph. Stern ) បានកំណត់រចនាបទបន្ថែមមួយទៀតក្នុងចំណោមរចនាបទនៃសិល្បៈខ្មែរគឺ "**រចនាបទគូលែន**" ដែលស្ថិតនៅចន្លោះសិល្បៈខ្មែរសម័យមុនអង្គរ និង សម័យអង្គរ។ រចនាបទនេះត្រូវបានកំណត់កាលបរិច្ឆេទនៅដើមសតវត្សទី៩ ហើយបានជះឥទ្ធិពលទៅសម័យកាលក្រោយៗមកទៀត។

ដើម្បីឈានទៅកំណត់រចនាបទថ្មី ដែលមានឈ្មោះថា "រចនាបទគូលែន" នេះលោក ស្ទែន បានសិក្សានិងវិភាគទៅលើធាតុសំខាន់ចំនួនបីគឺ សសរពេជ្រ ផ្តែរទ្វារ និងរូបបដិមា។ លោកបានកត់សំគាល់ឃើញថាសសរពេជ្រមានលក្ខណៈពិសេស



ប្រាសាទរោងចិន



ប្រាសាទដំរីក្រាប

www.elibraryofcambodia.org



ប្រាសាទតាផុង



ប្រាសាទក្រោលរមាស

ដោយឡែកដែលបញ្ជាក់ពីរចនាបទគូលែន។ ចំណែកផ្តែរទ្វារក៏បង្ហាញពីលក្ខណៈប្លែកមិនដូចរចនាបទមុនៗ ហើយក៏បានផ្តល់ជាគំរូដល់រចនាបទបន្តបន្ទាប់ផងដែរ។

ទោះជាយ៉ាងណា ក៏ការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យានៅលើភ្នំគូលែនមិនទាន់ត្រូវបានបញ្ចប់នៅឡើយទេ។ រហូតមកដល់ដើមសតវត្សទី២១នេះស្លាកស្នាមនិងទីតាំងបុរាណមួយចំនួនទៀតត្រូវបានរកឃើញជាពិសេសទីតាំងប្រាសាទបុរាណ និងស្ថានីយបុរាណ។ប៉ុន្តែប្រាសាទបុរាណដែលត្រូវបានរកឃើញនាសម័យកាលក្រោយមកនេះ ជាទូទៅពុំបន្សល់ទុកនូវរូបភាពសំណង់គួរឲ្យកត់សំគាល់នោះទេ គឺនៅសល់តែគ្រឿងលំអស្ថាបត្យកម្មមានដូចជាផ្តែរទ្វារ ស៊ុំទ្វារ សសរពេជ្រ ឥដ្ឋ ថ្មបាយក្រៀម ឬជើងទម្រ របចម្លាក់តែប៉ុណ្ណោះ។ ម៉្យាងទៀតទីតាំងប្រាសាទបុរាណទាំងនោះ

www.elibraryofcambodia.org

ពុំទាន់មានឈ្មោះសម្រាប់កំណត់នៅឡើយ ហើយរហូតមកដល់ពេលនេះប្រាសាទបុរាណ ត្រូវបានរកឃើញមានចំនួនជិត៥០ទីតាំង។

## ៣-២-ពើង

អ្នកស្រាវជ្រាវសម័យដើមមិនត្រឹមតែបានយកចិត្តទុកដាក់សិក្សា និងកត់ត្រាប្រាសាទបុរាណមួយ ចំនួនដែលខ្លួនបានជួបប្រទះប៉ុណ្ណោះទេប៉ុន្តែបានចាប់អារម្មណ៍ទៅលើបុរាណស្ថានផ្សេងៗទៀតមានដូចជាពើង និងចម្លាក់បាតស្ទឹងជាដើម។ **ពើង** គឺជាបុរាណស្ថានមួយដែលមានលក្ខណៈប្រវត្តិសាស្ត្រ និងជាវត្ថុតាងសំខាន់ផងដែរ សម្រាប់អ្នកសិក្សាស្រាវជ្រាវ។ នៅដើមសតវត្សទី២០ លោក អែម៉ូនីញេ (E. Aymonier) ក៏ដូចជាលោក លុយណេ ដឺឡាហ្សុងគៀរ (E. Lunet Delajonquière) បានសិក្សា និង កត់ត្រាពើងបុរាណមួយចំនួនមានដូចជា ពើងព្រះទ្វារ ពើងព្រះពុទ្ធលើ ពើងព្រះពុទ្ធក្រោម ពើងឆ័ត្រ និងពើងគំនូរជាដើម។

ពើងគឺជាផ្ទាំងថ្មធំៗ ឬល្បាក់ថ្មភ្នំ ដែលមានចម្លាក់ ឬរូបគំនូរផ្សេងៗ ហើយភាគច្រើនសុទ្ធសឹង ជាទីគោរពបូជា ជូនកាល



ពើងត្បាល់



ពើងព្រះអង្គធំ

www.elibraryofcambodia.org



ពើងគំនូរ



ពើងគំនូរ

មានសណ្ឋានជាល្អាងផងដែរ ។ នៅលើភ្នំគូលេន គេបានជួបប្រទះពើងជាច្រើន ប្រភេទ ក្នុងនោះពើងមួយចំនួនបានបង្ហាញពីគំនូសលើថ្មជារូបទោល ជាតួអង្គអាទិទេព ឬជារូបសត្វ ដែលជាយានជំនិះរបស់អាទិទេព រីឯពើងមួយចំនួនទៀតឆ្លាក់លំអជាចម្លាក់លៀន បង្ហាញពីតួអង្គអាទិទេពក្នុងរូបភាពដកស្រង់ចេញពីទេវកថា ចំណែកពើងមួយប្រភេទទៀតបង្ហាញពីរូបគំនូរ លំអជារូបផ្សេងៗ ដោយមានស្លាកស្នាមពណ៌ជិតនៅលើជញ្ជាំងថ្ម។ ក្នុងចំណោមពើងខាងលើនេះ ពើងមួយចំនួន មានបន្សល់ទុកនូវអក្សរចារឹកទៀតផង ដែលជាស្លាកស្នាមសំខាន់ និងជាកម្មវត្ថុនៃការសិក្សាស្វែងយល់អំពីប្រវត្តិ ឬរឿងរ៉ាវទាក់ទងនឹងភ្នំគូលែន។ ដូចជាសិលាចារឹកនៃពើងគំនូរ ដែលមានលេខសំគាល់ K. 230 ចារឡើងនាសតវត្សទី១១ បានបញ្ជាក់អំពីពាក្យថា មហេន្រ្ទ (មហេន្ទ្របព៌ត) ដែលជាឈ្មោះនៃភ្នំគូលែន។

ទោះជាមានការកត់ត្រា និងចាប់អារម្មណ៍ពីសំណាក់អ្នកស្រាវជ្រាវមួយចំនួនចំពោះ "ពើង" ដែលជាបុរាណស្ថានដ៏មានសារៈសំខាន់ សម្រាប់ការបកស្រាយអំពីប្រវត្តិសាស្ត្រយ៉ាងណាក៏ដោយក៏ការសិក្សាស៊ីជម្រៅពុំទាន់លេចចេញជារូបរាងនៅឡើយ។ ដោយហេតុថា ក្នុងចំណោមពើង ដែលមាននៅលើភ្នំគូលែន ពើង



www.elibraryofcambodia.org

មួយចំនួនទំនងជាបានបន្សល់ទុកស្លាកស្នាមតាំងពីសម័យមុនប្រវត្តិសាស្ត្រមកម្ល៉េះ ដូចជាពើងតាខាប មានគំនូរជារូបសត្វពណ៌ក្រហមនៅលើជញ្ជាំង។ ចំណែកពើងខ្លះទៀតបានរំលេចឲ្យឃើញពីក្បូរក្បាច់ រចនាជារូបអាទិទេព ឬរឿងរ៉ាវទាក់ទងនឹងអាទិទេពធំៗនៃលទ្ធិព្រហ្មញ្ញសាសនា ដែលមានឥទ្ធិពលពីឥណ្ឌា ក្នុងនោះមានពើងត្បាល់ និងពើងគំនូរជាដើម។ ម្យ៉ាងទៀត យើងសន្និដ្ឋានថាចម្លាក់លំអ ដែលដូនតាខ្មែរបានរចនាឡើងនៅលើពើងនានានៃរាជធានីមហេន្ទ្របព៌តនេះ ទុកដូចជាគំរូ ឬជាដើមហេតុមួយដែលនាំឲ្យសិល្បករខ្មែរសម័យអង្គរចម្លងយក ដើម្បីរចនាលំអនៅលើជញ្ជាំងប្រាសាទនានា បានយ៉ាងល្អឥតខ្ចោះ។

ពើងដែលត្រូវបានរកឃើញនៅលើភ្នំគូលែន មានចំនួនសរុប៣៩កន្លែង។

## ៣-៣-ចម្លាក់បាតស្ទឹង

ទាក់ទងនឹងបញ្ហាជំនឿ ភ្នំគូលែនជាមជ្ឈមណ្ឌលកណ្តាលមួយ ដែលប្រមូលផ្តុំទៅដោយសំណង់ និងទីតាំងបុរាណច្រើនប្រភេទត្រូវបានកសាងឡើងដើម្បីបំរើឲ្យជំនឿសាសនា ហើយដែលមានឥទ្ធិពលក្នុងសង្គមខ្មែរ ទាំងអតីតកាល និងបច្ចុប្បន្នកាល។

ចម្លាក់បាតស្ទឹង ជាស្នាដៃសិល្បៈមួយប្រភេទរបស់បុព្វបុរសខ្មែរដែលបង្កប់នូវអត្ថន័យសំខាន់ខាងជំនឿសាសនា។ បើទោះបីជាភ្នំគូលែនត្រូវបានចាត់ទុកថាជាលំនៅស្ថាននៃព្រះសិវៈ ឬជាភ្នំពិសិដ្ឋ ប្រកបដោយបារមីយ៉ាងណាក៏ដោយ ក៏ដូនតាខ្មែរបានរៀបចំបង្កើតឲ្យមានជារូបចម្លាក់ដោយការឆ្លាក់ជារូបសិវៈលិង្គ និងទេវរូបផ្សេងៗ ស្ថិតនៅបាតនៃផ្លូវទឹក ដែលហូរចុះពីភ្នំគូលែនទៅរកទីប្រជុំជន ប៉ែកខាងក្រោម មានដូចជា រាជធានីហរិហរាល័យ (ក្រុងរលួស) និងរាជធានីយសោធរបុរៈ (ក្រុងអង្គរ)។ ការធ្វើរបៀបនេះមានន័យថា បុព្វបុរសខ្មែរមានបំណងធ្វើឲ្យទឹកដែលហូរឆ្លងកាត់ "សិវលិង្គ" ទាំងនោះក្លាយទៅជាទឹកមន្តដ៏ពិសិដ្ឋ ឬទឹកអម្រឹតដើម្បីទុកប្រើប្រាស់ និងបំរើឲ្យពិធីលាងជម្រះភាពឧបទ្រពចង្រៃ សៅហ្មងពីប្រជារាស្ត្រផងទាំងពួង។

ប្រជារាស្ត្ររស់នៅក្រុងអង្គរពុំបានប្រើប្រាស់ទឹកស្ទឹងសៀមរាប សម្រាប់ការចុះមុជទឹកប្រចាំថ្ងៃនោះឡើយ ដោយសារមិនមែនជាទឹកធម្មតា ប៉ុន្តែជាទឹកពិសិដ្ឋ។ ចំណុចនេះបានគូសបញ្ជាក់តាមរយៈសិលាចារឹកនៃប្រាសាទបាទជុំ (ស្ថិតនៅតំបន់អង្គរ)។ លោក ហ្សក សឺដែស (G. Coedès) ជាជនជាតិបារាំង និងជាអ្នកសិក្សាខាងអក្សរចារឹកដ៏ល្បីល្បាញមួយរូប បានបកប្រែ

www.elibraryofcambodia.org



ចម្លាក់ព្រះស្ដេ្ព(លិង្គមួយពាន់)



ចម្លាក់លិង្គមួយពាន់

សិលាចារឹកនេះថា "គ្មាននរណាម្នាក់ចុះមុជទឹកស្ទឹងដែលមានប្រភពមកពី**ភ្នំមហេន្ទ្រ** ជា**ភ្នំពិសិដ្ឋ** នោះឡើយ"។

### ៣-៤-ចម្លាក់ព្រះពុទ្ធរូប

ក្រៅពីរូបចម្លាក់ប្រាសាទបុរាណ និងស្ថានីយបុរាណខាងព្រហ្មញ្ញសាសនាភ្នំគូលែនបាននិងកំពុងមានភាពល្បីល្បាញ ដោយទទួលបាននូវការចាប់អារម្មណ៍ពីសំណាក់ពុទ្ធសាសនិកជនទាំងឡាយមកពីគ្រប់ទិសទីនៃព្រះរាជាណាចក្រ។អ្នកមានជំនឿតែងបានមក



www.elibraryofcambodia.org

ប្រារព្ធពិធីសាសនា ឬក៏រៀបចំពិធីបន់ស្រន់ផ្សេងៗ ដើម្បីសុំសេចក្តីសុខ និងឲ្យសម្រេចបានទៅតាមការប៉ងប្រាថ្នារបស់ខ្លួន ពីទីតាំងពុទ្ធសាសនានៅលើភ្នំគូលែន។

បន្ទាប់ពីព្រះពុទ្ធសាសនាបានរីកចម្រើននិងចូលជ្រួតជ្រាបដល់ស្រទាប់មហាជន ក្រោយពីការធ្លាក់ចុះនៃឥទ្ធិពលព្រហ្មញ្ញសាសនាក្នុងសង្គមខ្មែរ ចាប់ពីសតវត្សទី១៦តរៀងមក ការកសាងវត្តអារាម ឬទីគោរពបូជាខាងព្រះពុទ្ធសាសនាក៏ចាប់ផ្តើមកើតមានគ្រប់ទីកន្លែង។ សំណង់ពុទ្ធសាសនាក្រោយមកនេះភាគច្រើនត្រូវបានកសាងឡើងនៅក្បែរទីតាំងបុរាណ ដែលធ្លាប់ជាទីគោរពបូជាខាងព្រហ្មញ្ញសាសនា ជួនកាលត្រូវបានស្ថាបនានៅពីលើទីតាំងប្រាសាទបុរាណ ដោយការរុះរើប្រាសាទបុរាណនោះចេញ។

ចម្លាក់ព្រះពុទ្ធរូបដ៏ធំមួយអង្គ ដែលមានទីតាំងស្ថិតនៅវត្តព្រះអង្គធំ លើភ្នំគូលែន ត្រូវបានកសាងឡើងដោយស្ថិតនៅក្បែរស្ថានីយបុរាណ (មានពើង និងប្រាសាទបុរាណ)។ សមិទ្ធិផលនេះបានបង្ហាញ ឲ្យឃើញពីស្នាដៃដ៏អស្ចារ្យរបស់សិល្បករបុរាណដែលបានខិតខំកែច្នៃ និងឆ្លាក់ថ្មភ្នំដ៏ធំ បង្កើតបានជា ព្រះពុទ្ធរូបមួយអង្គស្ថិតក្នុងឥរិយាបទផ្ទំ "ចូលបរិនិព្វាន" បានយ៉ាងល្អ។ ព្រះពុទ្ធរូបអង្គនេះមានបណ្តោយជិត១០ម៉ែត្រ ផ្ទំសណ្តកទៅទិសអាគ្នេយ៍ និងមានដងខ្លួនគ្របពាសទៅដោយពណ៌មាស។ ពុទ្ធសាសនិកជនដែលបានទៅដល់ទីនោះ តែងបានឡើងទៅបូជាធូបទៀន និងបន់ស្រន់ ជួនកាលមានថ្វាយសន្លឹកមាស ដើម្បីបិទពាសពីលើដងខ្លួនរបស់ព្រះអង្គទៀតផង។ ការយកសន្លឹកមាសទៅពាសពីលើព្រះពុទ្ធបដិមាត្រូវបានអនុវត្តនៅគ្រប់កន្លែង នៅលើដែនដី ដែលប្រណិប័តន៍ព្រះពុទ្ធសាសនានៅអាស៊ីអាគ្នេយ៍ មានដូចជា ខ្មែរ ឡាវ ថៃ និងមីយ៉ាន់ម៉ា( ភូមា )ជាដើម។



**ព្រះអង្គធំ**

www.elibraryofcambodia.org

យោងតាមសិលាចារឹក ដែលមានលេខសំគាល់ K.715 ចារឡើងនៅឆ្នាំ១៥៨៦នៃគ្រឹស្តសករាជ ពុទ្ធសាសនិកជនខ្មែរសម័យក្រោយអង្គរបានថ្វាយព្រះនាមដល់ព្រះអង្គធំថា **ព្រះខ្សុទ** ដែលមានន័យថា "កំពូលភ្នំដ៏ពិសិដ្ឋ" ។

## ៣-៥-ទំនប់បុរាណ

ក្រៅពីសំណង់និងទីកន្លែងសម្រាប់គោរពបូជា ឬបម្រើឲ្យជំនឿសាសនា ភ្នំគូលែនបានបន្សល់ទុកនូវសំណង់ប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់ជាច្រើនទៀត ដែលបំរើឲ្យជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជារាស្ត្រ និងបង្ហាញពីភាពចម្រុងចម្រើននៃអាណាចក្រខ្មែរ។ សំណង់ទាំងនោះបានគូសបញ្ជាក់ពីស្នាដៃដែលពោរពេញទៅដោយទេពកោសល្យដ៏ប៉ិនប្រសប់នៃវិស្វករខ្មែរបុរាណក្នុងការសិក្សា និងកែច្នៃធម្មជាតិដើម្បីបម្រើ ឬបំពេញសេចក្តីត្រូវការរបស់សហគមន៍ និងសង្គមរបស់ខ្លួន។

តាមរយៈការស្រាវជ្រាវដល់ទីកន្លែង លោក វាន លីអែរ (Van Liere WJ) ជាអ្នកស្រាវជ្រាវផ្នែក ការគ្រប់គ្រងទឹកសម័យបុរាណបានបញ្ជាក់ឲ្យដឹងថាទីក្រុងបុរាណ មហេន្ទ្របព៌តត្រូវបានបង្កើតឡើងដោយមានប្រព័ន្ធធារាសាស្ត្រដែលមានតួនាទីសំខាន់ក្នុងការគ្រប់គ្រងទឹក ទុកប្រើប្រាស់ប្រចាំថ្ងៃ។ ការរកឃើញសំណង់ធារាសាស្ត្រនេះត្រូវបានបញ្ជាក់បន្ថែម ដោយការស្រាវជ្រាវតាមប្រព័ន្ធបច្ចេកវិទ្យាថ្មី ទំនើប ហៅថា LiDaR (Light Detecting and Ranging) តាមរយៈការថតរូបភាពពីលើអាកាស។



ទំនប់ថ្មល់ម្រេច

"ទំនប់" ជាផ្នែកមួយនៃប្រព័ន្ធធារាសាស្ត្រ ដែលមានតួនាទីទប់ ឬបង្ខាំងទឹកទុក ដើម្បីប្រើប្រាស់ ឬបម្រើឲ្យការរស់នៅប្រចាំថ្ងៃរបស់ប្រជាសហគមន៍ ប្រកបដោយនិរន្តរភាព។


www.elibraryofcambodia.org

ថ្វីត្បិតតែអាកាសធាតុមានលក្ខណៈអំណោយផលច្រើនដល់ការរស់នៅយ៉ាងណាក៏ដោយ ក៏ដូនតាខ្មែរបានខិតខំបង្កើតឲ្យមានហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដើម្បីបង្ការក្នុងពេលមានគ្រោះរាំងស្ងួត និងដើម្បីសម្រួលដល់ការរស់នៅផងដែរ។

ជាក់ស្តែងទំនប់បុរាណជាច្រើនត្រូវបានរកឃើញជាបន្តបន្ទាប់នៅលើភ្នំគូលែន ក្នុងនោះមានទំនប់ សំខាន់ចំនួនបីត្រូវបានលើកយកមកបង្ហាញ មានដូចជា ទំនប់ថ្នល់ម្រេច ទំនប់ស្រែត្បូង និងទំនប់ ស្រែជើង។ បច្ចុប្បន្នប្រជាសហគមន៍រស់នៅលើភ្នំគូលែនបានហៅទំនប់បុរាណនេះថា "ថ្នល់" ដូចជាថ្នល់ម្រេច និង ថ្នល់ត្បូងជាដើម។

តាមការស្រាវជ្រាវនិងពិនិត្យដល់ទីកន្លែង ទំនប់ថ្នល់ម្រេចជារបាំងទឹកមួយដែលមានទំហំធំជាងគេ ដោយមានបណ្តោយរហូតដល់មួយគីឡូម៉ែត្រ ទទឹងទំហំហុកសិបម៉ែត្រ និងកំពស់ប្រែប្រួលពីប្រាំទៅដប់ពីរម៉ែត្រ។ ម្យ៉ាងទៀតផ្ទៃជញ្ជាំងផ្នែកខាងក្នុងនៃទំនប់ត្រូវបានក្រាលពាសដោយថ្មបាយក្រៀម។

## ៣-៦-ឡបុរាណ

អ្នកស្រាវជ្រាវកាលពីសតវត្សមុនៗតែងបានពោលអះអាងថា "កុលាលភាជន៍" ដែលត្រូវបានរកឃើញតាមរយៈការធ្វើកំណាយនៅតាមស្ថានីយបុរាណនានាក្នុងព្រះរាជាណាចក្រ ត្រូវបាននាំចូលពីប្រទេសចិន ឬពីបរទេស។ ការធ្វើសេចក្តីសន្និដ្ឋានរបៀបនេះគឺដោយសារ អ្នកស្រាវជ្រាវទាំងនោះពុំមាន ភស្តុតាងគ្រប់គ្រាន់ ក្នុងការវិនិច្ឆ័យឲ្យបានប្រាកដប្រជាថា បុព្វបុរសខ្មែរអាចមានសមត្ថភាពក្នុងការផលិតភាជន៍ ដើម្បីបំរើឲ្យសេចក្តីត្រូវការប្រចាំថ្ងៃនោះឡើយ។ ប៉ុន្តែលោក អៃម៉ូនីញេ ធ្លាប់បង្ហើបឲ្យដឹងអំពីទីតាំងផលិតកុលាលភាជន៍សម័យបុរាណនៅលើភ្នំគូលែនតាំងពីដើមសតវត្សទី២០មកម្ល៉េះ។

រហូតមកដល់ចុងសតវត្សទី២០ ភាពចៃដន្យមួយបានកើតមានឡើង ដែលនាំទៅដល់ការសិក្សា ឡបុរាណ ជាទ្រង់ទ្រាយធំ។ ហេតុការណ៍នេះបានកើតឡើង ដោយការឈូសបង្កើតផ្លូវមួយខ្សែក្នុងឃុំលលៃ នៃស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ផ្លូវថ្មីមួយខ្សែនេះស្ថិតនៅក្បែរទីតាំងឡបុរាណ ដែលអ្នកស្រាវជ្រាវបានដាក់ឈ្មោះថា "ឡបាកោង"។ ចាប់ពីពេលនោះ ឡបុរាណ

www.elibraryofcambodia.org

ជាច្រើនត្រូវបានរកឃើញ និងសិក្សាស្រាវជ្រាវ មានដូចជា ឡបាកោង ឡតានី ឡខ្នាពោ ឡសរសី និងឡថ្នល់ម្រេច (លើភ្នំគូលែន) ជាដើម។



ឡថ្នល់ម្រេច

នៅអំឡុងឆ្នាំ១៩៩៩ អាជ្ញាធរអប្សរា រួមសហការជាមួយស្ថាប័នស្រាវជ្រាវអន្តរជាតិ មានវិទ្យាស្ថានណារ៉ា និងវិទ្យាស្ថានសូហ្វីយ៉ានៃប្រទេសជប៉ុន បានរួមគ្នាចុះសិក្សាស្រាវជ្រាវ និងធ្វើកំណាយនៅឡអន្លង់ធំ ឬឡថ្នល់ម្រេច ដែលមានទីតាំងស្ថិតនៅភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប ដើម្បីសិក្សា និងស្វែងយល់ពីរចនាសម្ព័ន្ធរបស់ឡ។ នៅលើផ្ទៃដីដែលមានបណ្ដោយប្រវែង២០០ម៉ែត្រ និងទទឹង៨០ម៉ែត្រ គេបានរកឃើញឡបុរាណជាច្រើន ស្ថិតនៅជាជួរបន្តបន្ទាប់គ្នាហើយឡនីមួយៗមានទំហំពី១០ ម៉ែត្រ ទៅ១៥ម៉ែត្រ។

តាមការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវ ឡថ្នល់ម្រេចត្រូវបានប្រើប្រាស់សម្រាប់ដុតកុលាលភាជន៍ ផ្សំឡើងពីដីឥដ្ឋពណ៌សដែលមានជាតិដែកតិចក្នុងរង្វង់ពី០,៧ទៅ២ភាគរយហើយបង្កើតបានជាភាជន៍ ដែលមានស្រទាប់រលោងពណ៌បៃតង។ សំណល់វត្ថុតាងដែលជាសមិទ្ធិផលនៃឡបុរាណនេះ ត្រូវបានរកឃើញមានដូចជា កោដ្ឋ ជន្លាប់ ខួច ចានគម សន្លឹកក្បឿង សន្លឹកព្រំដំបូល និងសន្លឹករកា (លំអដំបូលផ្ទះ) ជាដើម។ អ្នកស្រាវជ្រាវបានបន្តសន្និដ្ឋានថា ឡបុរាណនេះត្រូវបានបង្កើតឡើងនៅសតវត្សទី៩។


www.elibraryofcambodia.org

## ៣-៧-ជណ្តើរបុរាណ

ភ្នំគូលែនត្រូវបានចាត់ទុកថាជា "ខ្ពង់រាប" ដែលមានកំពស់ប្រែប្រួលពី៣០០ម៉ែត្រទៅ៤០០ម៉ែត្រ និងមានបណ្តោយជាង



ជណ្តើរចៃរ៉ៃ

៤០គីឡូម៉ែត្រ សណ្តូកលើអ័ក្សដែលមានទិសដៅពីទិសពាយ័ព្យទៅទិសអាគ្នេយ៍។ នៅដើមសតវត្សទី៩ ព្រះបាទជ័យវរ្ម័នទី២បានជ្រើសរើសយកភ្នំគូលែន ដើម្បីប្រារព្ធពិធី "ទេវរាជ" និងធ្វើជារាជធានីសម្រាប់ទ្រង់គង់នៅមួយរយៈ។

នៅសម័យនោះ ដូនតាខ្មែរបានខិតខំបង្កើតហេដ្ឋារចនាសម្ព័ន្ធចំនួនពីរប្រភេទសម្រាប់ឡើងចុះភ្នំ គឺផ្លូវជំរី និងជណ្តើរ។ សព្វថ្ងៃ ផ្លូវជំរីបានក្លាយមកជាផ្លូវទំនាក់ទំនងដ៏សំខាន់សម្រាប់ការធ្វើដំណើរឡើងចុះ ជាប្រចាំពីសំណាក់សហគមន៍រស់នៅលើភ្នំគូលែន ក៏ដូចជាភ្ញៀវទេសចរទាំងឡាយ។ ចំណែកជណ្តើរវិញ បានទទួលរងនូវការខូចខាតស្ទើរទាំងស្រុង ។

រហូតមកដល់ពេលនេះ យើងបានជួបប្រទះជណ្តើរបុរាណតែមួយគត់ ដែលមានទីតាំងស្ថិតនៅ ភូមិតាហាន ឃុំខ្នងភ្នំ ស្រុកស្វាយលើ។ អ្នកស្រុកបានដាក់ឈ្មោះជណ្តើរបុរាណនេះថា "ជណ្តើរចៃរ៉ៃ"។ ជណ្តើរចៃរ៉ៃនេះមានកំពស់ជិត២០០ម៉ែត្រ និងមានទទឹងប្រហែល៥ម៉ែត្រ តភ្ជាប់ពីភូមិត្បែងខាងកើត ( ស្ថិតនៅជើងភ្នំ ) ឡើងមកភ្ជាប់ភូមិតាហាននៅលើភ្នំ។ ជណ្តើរបុរាណនេះកសាងឡើងអំពីថ្មបាយក្រៀម ដែលមានសណ្ឋានជាដុំធំៗ តម្រៀបផ្តុំជាថ្នាក់ៗ ហើយកន្លែងខ្លះមានការចាំងថ្មភ្នំធ្វើជាកាំជណ្តើរផងដែរ។

www.elibraryofcambodia.org

## ៣-៨-ស្រះដំរី

ដូចបានរៀបរាប់ខាងលើភ្នំគូលែនបានរក្សាទុកនូវសំណង់បុរាណច្រើនប្រភេទទាំងសំណង់ខាងសាសនា និងសំណង់ស៊ីវិលដែលមានសារៈសំខាន់ដល់សង្គម។ សំណង់បុរាណទាំងឡាយនោះទទួលបាននូវការចាប់អារម្មណ៍ពីអ្នកស្រាវជ្រាវ និងត្រូវបានលើកយកមកសិក្សា ឬក៏ជាប្រធានបទសំខាន់សម្រាប់ការស្រាវជ្រាវ និងស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរសម័យបុរាណ។



ស្រះដំរី

រហូតមកដល់ពេលនេះ យើងពុំឃើញមានឯកសារ ដែលសរសេរ និងវិភាគអំពីសំណង់ស្ថាបត្យកម្មបុរាណចុងក្រោយនេះ ដែលមានឈ្មោះថា ស្រះដំរីនោះឡើយ។ ប៉ុន្តែកាលពីពាក់កណ្ដាលសតវត្សទី២០ លោក ប៊ូលបេ (J. Boulbet) អ្នកស្រាវជ្រាវបារាំង ធ្លាប់សន្និដ្ឋានថាសំណង់ស្រះដំរីនេះ ពិតជាស្ថិតក្នុងសម័យកាលគូលែន នាដើមសតវត្សទី៩។ ក្នុងនោះលោកបានសិក្សា និងវិភាគលើចម្លាក់រូបសត្វតោ ដោយធ្វើការប្រៀបធៀបជាមួយចម្លាក់តោនៅក្រុមប្រាសាទសម្បូរព្រៃគុក ក្នុងខេត្តកំពង់ធំ។

ទោះជាយ៉ាងណាក៏សំណង់ស្រះដំរីនេះបានស្ថិតនៅជាអាថ៌កំបាំង ដោយពុំមាននរណាម្នាក់ដឹងថាវាមានតួនាទីសំខាន់អ្វីនៅសម័យកាលនោះឡើយ។ ពិនិត្យជារួម "ស្រះដំរី" ប្រហែលត្រូវបានដាក់ឈ្មោះ ដោយសារនៅទីនោះ មានរូបចម្លាក់សត្វដំរីមួយយ៉ាងធំឈរបែរមុខទៅទិសខាងលិច និងស្រះទឹកធំល្មមមួយស្ថិតនៅចំពីមុខ។ ប៉ុន្តែនៅខាងស្ដាំចម្លាក់សត្វដំរី ក៏មានចម្លាក់សត្វតោចំនួន២ក្បាល រួមជាមួយសត្វខ្លាមួយក្បាលផងដែរ។ ទាំងចម្លាក់សត្វដំរី និងសត្វតោ ត្រូវបានរចនាឡើងអំពីថ្មភ្នំធម្មជាតិមួយដុំ ដែលស្ថិតនៅទីនោះស្រាប់ហើយមានគម្លាតឆ្ងាយ


www.elibraryofcambodia.org

ពីគ្នាប្រហែល៦ម៉ែត្រ ហាក់ដូចជាស្ថិតនៅអមសង្ខាងផ្លូវ។

ចម្លាក់សត្វដំរី និងសត្វគោដ៏ធំទាំងនោះពិតជាតឹកតាងដ៏សំខាន់ និងបានបង្ហាញឲ្យឃើញអំពីស្នាដៃ និងទេពកោសល្យដ៏ប៉ិនប្រសព្វរបស់សិល្បករខ្មែរសម័យបុរាណ ដែលជាវិស្វករដ៏ចំណានបម្រើឲ្យសង្គមជាតិ។ ចម្លាក់ទាំងនោះបានជះឥទ្ធិពល និងជាគំរូមួយសម្រាប់សម័យកាលក្រោយៗ។

## ៣-៩ ការដ្ឋានយកថ្មបុរាណ

ពីឆ្នាំ៨០២គ.ស ដោយចាប់គិតពីពេលដែលព្រះបាទជ័យវរ្ម័នទី២ បានប្រកាសឯករាជ្យពីពួកជ្វា រហូតដល់ការចាកចោលក្រុងអង្គរនៅឆ្នាំ១៤៣២គ.ស ក្នុងរាជ្យព្រះបាទពញាយ៉ាត ដែលមានរយៈពេល៦៣០ឆ្នាំមកនោះ ការប្រើប្រាស់ថ្មភក់គឺមានទំហំធំនៅចុងសតវត្សទី៩ រហូតដល់សតវត្សទី១៣ មានរយៈពេលប្រមាណ៤០០ឆ្នាំ។

តើថ្មទាំងឡាយនោះមានប្រភពមកពីណា? តាមការស្រាវជ្រាវ គេបានរកឃើញកន្លែងយកថ្មមួយចំនួននៅតំបន់ភ្នំគូលែន ដូចជានៅអូរថ្មដាប់ ដែលនៅទីនោះថ្មមានគុណភាពល្អសម្រាប់យកទៅសាងសង់ប្រាសាទនានា។ នៅខាងលើភ្នំគូលែន នៅតំបន់ប្រាសាទរោងចិនក៏ជាការដ្ឋានយកថ្មមួយដែរ តែគុណភាពថ្មនៅទីនោះមានគ្រាប់ធំ ដែលមិនអាចយកទៅប្រើប្រាស់សម្រាប់កសាងប្រាសាទឲ្យបានល្អឡើយ ប៉ុន្តែអាចយកធ្វើជាគ្រឹះ ឬកន្លែងមិនចាំបាច់ផ្សេងៗទៀត។ តាមព័ត៌មានរបស់ប្រជាជនអាចមានកន្លែងផ្សេងៗទៀត ដូចជានៅតាមជើងភ្នំគូលែន ក្បាលស្ពាន និងភ្នំនៅក្បែរនោះ ដែលទាមទារអោយមានការសិក្សា និងរុករកបន្ថែមទៀត។



**កន្លែងយកថ្មក្បែរភូមិអន្លង់ធំ**

www.elibraryofcambodia.org

## ៤-សហគមន៍មូលដ្ឋាន

កាលពីពាក់កណ្ដាលសតវត្សទី១៩ អ្នកស្រាវជ្រាវបារាំងធ្លាប់បង្ហើបឲ្យដឹងថា នៅលើខ្នងភ្នំគូលែនមានសហគមន៍មនុស្សរស់តាមរបៀបបុរាណ។ យោងតាមសិលាចារឹកស្ដុកកក់ធំ ដែលមានលេខសំគាល់ K.235 ចារឡើងនៅអំឡុងសតវត្សទី១១ ភ្នំគូលែនជាទីតាំងនៃរាជធានីបុរាណ ដែលត្រូវបានកសាងឡើងក្នុងរាជរបស់ព្រះបាទជ័យវរ្ម័នទី២នាដើមសតវត្សទី៩ និងមានឈ្មោះថា មហេន្ទ្របព៌ត(លំនៅស្ថានរបស់ព្រះឥសូរ អាទិទេពកំពូលនៃព្រហ្មញ្ញសាសនា)។ ព័ត៌មាននេះបានបញ្ជាក់ឲ្យដឹងថា ភ្នំគូលែនជាទីតាំងមួយដែលប្រមូលផ្ដុំទៅដោយភូមិដ្ឋាន និងមានមនុស្សរស់នៅកុះករ។

រហូតមកដល់បច្ចុប្បន្ន ភ្នំគូលែននៅតែជាទីតាំងមួយដែលប្រមូលផ្ដុំទៅដោយភូមិដ្ឋានចំនួន១០ ក្នុងនោះភូមិចំនួនពីរស្ថិតនៅក្រៅបញ្ជីរបស់អាជ្ញាធរដែនដី (ភូមិតាហាន និងភូមិតាវីរៈកាត់)។ យោងតាមលទ្ធផលស្រាវជ្រាវកាលពីឆ្នាំ២០១២ ភ្នំគូលែនមានប្រជាពលរដ្ឋរស់នៅចំនួន៣៩៦៨នាក់ ចែកចេញជា៨៤៧គ្រួសារ ស្ថិតក្នុងឃុំខ្នងភ្នំនៃស្រុកស្វាយលើ។ កំណើនប្រជាពលរដ្ឋ ឬការកើនឡើងនៃអ្នកចំនូលថ្មី បានចាប់ផ្ដើមនៅឆ្នាំ២០០០ ស្របពេលតំបន់ភ្នំគូលែនទទួលបាននូវសុវត្ថិភាពសន្តិសុខពេញលេញ និងមានភៀវទេសចរក្នុងស្រុក។ ប៉ុន្តែជាដំបូងចំនួនប្រជាពលរដ្ឋមានកំណើនតិចតួចរហូតដល់ឆ្នាំ២០០៦។

បន្ទាប់មកចំនួនប្រជាពលរដ្ឋមានកំណើនគួរឲ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ២០០៦ រហូតដល់ឆ្នាំ២០១២។ ក្នុងនោះបើធ្វើការប្រៀបធៀបចាប់ពីឆ្នាំ២០០៦រហូតដល់ឆ្នាំ២០១២ ចំនួនប្រជាពលរដ្ឋមានកំណើន១៩ភាគរយ។ តួលេខខាងលើនេះបានបញ្ជាក់ឲ្យដឹងថា ក្នុងមួយឆ្នាំៗចំនួនប្រជាពលរដ្ឋបានកើនឡើងចំនួន៣,២ ភាគរយ សម្រាប់ឃុំខ្នងភ្នំទាំងមូល។ ប៉ុន្តែកំណើនប្រជាពលរដ្ឋខាងលើនេះមានទំហំ ខុសៗគ្នាទៅតាមភូមិដ្ឋាននីមួយៗ។ ក្នុងនោះភូមិព្រះអង្គធំមានកំណើនប្រជាពលរដ្ឋខ្ពស់ជាងគេ។ បើពិនិត្យតួលេខភូមិព្រះអង្គធំមានកំណើន៧២,៤ ភាគរយ ក្នុងអំឡុងពេលដប់ឆ្នាំចុងក្រោយនេះចាប់ពីឆ្នាំ២០០២ រហូតដល់ឆ្នាំ២០១២។ ប៉ុន្តែនៅរយៈពេល២ឆ្នាំចុងក្រោយ ចំនួនប្រជាពលរដ្ឋរស់នៅក្នុងភូមិព្រះអង្គធំមានកំណើនរហូតដល់២៥ ភាគរយ។ រហូតមកដល់ពេលនេះ បើពិនិត្យចំនួនខ្នងផ្ទះក្នុងភូមិព្រះអង្គធំ មានផ្ទះចំនួន២២៨ខ្នង ក្នុងនោះផ្ទះប្រក់ក្បឿងចំនួន៤


www.elibraryofcambodia.org

ផ្ទះប្រក់ស័ង្កសីចំនួន១៦១ ផ្ទះប្រក់ហ្វីប្រូចំនួន៥៣ និងផ្ទះប្រក់ស្លឹកចំនួន១០។

## ៥-ទិសដៅអភិរក្ស និងអភិវឌ្ឍន៍

ដូចបានបញ្ជាក់ជូនខាងលើ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម "ភ្នំគូលែន" មិនត្រឹមតែជាទីតាំងភូមិសាស្ត្រមួយដែលជាជង្រុកនៃធនធានធម្មជាតិដ៏សម្បូរបែបប៉ុណ្ណោះទេ ប៉ុន្តែជាទីតាំងប្រវត្តិសាស្ត្រដ៏ល្បីល្បាញមួយនៅក្នុងតំបន់ និងជាប្រភពនៃដើមកំណើតនៃអារ្យធម៌អង្គរ ដែលតំណាងឲ្យអត្តសញ្ញាណនៃជាតិសាសន៍ខ្មែរ។

ដោយយល់ដឹងអំពីសារៈសំខាន់ខាងលើនេះក្រសួងបរិស្ថានដឹកនាំដោយ**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រី មានគោលបំណងច្បាស់លាស់ក្នុងការថែរក្សា ការពារ និងអភិរក្សឲ្យបានគង់វង្សនូវធនធានធម្មជាតិ និងមត៌កវប្បធម៌ដ៏សម្បូរបែប ដែលកំពុងទទួលរងនូវការគម្រាមកំហែងធ្ងន់ធ្ងរតាមគ្រប់រូបភាព និងឈានទៅរកក្តីវិនាសអន្តរាយនាពេលខាងមុខ។ ក្រសួងបានត្រៀមរៀបចំដាក់ចេញនូវគម្រោងផែនការជាអាទិភាពក្នុងការគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម"ភ្នំគូលែន"ឲ្យមាននិរន្តរភាពក្នុងទិសដៅ





ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រី ចុះពិនិត្យឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម "ភ្នំគូលែន"

www.elibraryofcambodia.org

## ផែនទីទីតាំងប្រាសាទបុរាណ និង ស្ថានីយ៍បុរាណ ក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម "ភ្នំគូលែន" ខេត្តសៀមរាប






www.elibraryofcambodia.org

06026 08200693 006026 08

www.elibraryofcambodia.org



អគ្គនាយកដ្ឋានរដ្ឋបាលការពារ និង អភិរក្សធម្មជាតិ

www.elibraryofcambodia.org

9 789924 900306

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ ហីង ធារ៉ា
ខែសីហា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ